ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រម
លេខ ៥៧៨ "ច" ក្រ២
ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២៣
សំណុំរឿងជំនុំជម្រះលេខ ០៦
ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២៣

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២៣ វេលាម៉ោង ៨ និង ០០ នាទីព្រឹក ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមក្រុមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមក្រុមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះលេខ ០៦ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **សុភាព** ភេទប្រុស អាយុ ២៨ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ៖ នៅផ្ទះ ទីកន្លែងកំណើត នៅសង្កាត់[redacted] ក្រុងភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិធ្នោក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ផន "រ" ម្តាយឈ្មោះ [redacted] ស៊ីណា "រ" ប្រពន្ធឈ្មោះ [redacted] ចាន់ថន មានកូន ០២ នាក់ ។

ឃាត់ខ្លួនថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២០ ,ឃុំខ្លួនថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២២ (ម១) ។

ពីបទ **ស្រុបទោសបញ្ចូលគ្នា** ចំពោះសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១០៨៦ "ព"ក្រ៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០ ,សាលក្រមព្រហ្មទណ្ឌលេខ ៩៥ "ព" ក្រ៧ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ និងសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ២១៦៥ "ព" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

បានឃើញពាក្យសុំស្រុបទោសបញ្ចូលគ្នា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ របស់ទណ្ឌិតឈ្មោះ [redacted] សុភាព ។

បានឃើញសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១០៨៦ "ព"ក្រ៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

ផ្តន្ទាទោសឈ្មោះ [redacted] **សុភាព** ភេទប្រុស អាយុ ២៨ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បីឆ្នាំ) ។

Scanned with CamScanner

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ២១៣ កែងផ្លូវលេខ១៥៦ ភូមិ៦ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០២០ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

បានឃើញសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ៩៥ "ព" ក្រ៧ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់សាលាដំបូង រាជធានីភ្នំពេញ ។

ផ្តន្ទាទោសឈ្មោះ [redacted] **សុភាព** ភេទប្រុស អាយុ ២៨ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្លន ឆ្នាំ) ។

ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចមុខហាងលក់គ្រឿងសមុទ្រម៉ាប់អយស្ទ័រ ផ្លូវ លេខ២៩២ ស្ថិតនៅក្នុងភូមិ៣ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

បានឃើញសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ២១៦៥ "ព" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ របស់សាលាដំបូង រាជធានីភ្នំពេញ ។

ផ្តន្ទាទោសឈ្មោះ [redacted] **សុភាព** ភេទប្រុស អាយុ ២៨ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ ឆ្នាំ) ។

ពីបទ ធ្វើឱ្យខូតខាតដោយចេតនា ប្រព្រឹត្តនៅចំណុចផ្លូវក្រោយអាងភាពយន្តគីរីរម្យ សង្កាត់បឹងកេងកង២ ខណ្ឌ បឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៩ តាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

នាពេលសវនាការ

ទណ្ឌិតឈ្មោះ [redacted] **សុភាព** បានបញ្ជាក់ថា៖ ខ្ញុំបាទត្រូវតុលាការផ្តន្ទាទោសដោយសាលក្រមចំនួន០៣ ដែល សាលក្រមនិមួយៗបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ០៣ឆ្នាំ ,០៤ ឆ្នាំ និងរយៈពេល ០១ឆ្នាំ សរុបទាំងបីសាលក្រម រយៈពេលជាប់ពន្ធនាគារ ០៨ឆ្នាំ ហើយសាលក្រមនិមួយៗបានចូលស្ថាពរហើយ ។ ខ្លួនត្រូវផ្តន្ទាទោសតែបីសាលក្រមទេ ក្រៅពីនេះពុំមានទេ ពេលខ្លួនរស់នៅក្នុងពន្ធនាគារ ខ្លួនមិនដែលប្រព្រឹត្តបទល្មើស និងបង្កការលំបាកដល់ ទណ្ឌិតដូចគ្នា នៅក្នុងពន្ធនាគារទេ។ ហេតុនេះ ខ្លួនសុំឱ្យតុលាការស្រូបទោសខ្ញុំបញ្ចូលគ្នា ដើម្បីឱ្យខ្ញុំបានឆាប់ចេញពីមណ្ឌលអប់រំកែប្រែ និងមើលថែរម្តាយចាស់ជរា ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានឆ្លើយសុំ

បន្ទាប់ពីបានស្តាប់ចម្លើយទណ្ឌិតឈ្មោះ [redacted] សុភាព និងពាក្យសុំស្រូបទោសលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៨៨ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២០ ,សំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៥៤ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០២០ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៣០២០ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២០ ដែលសម្រេចតាមសាលក្រមព្រហ្មទណ្ឌស្ថាពរ លេខ ១០៨៦ "ព"ក្រ៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០ ,សាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ៩៥ "ព" ក្រ៧ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ និងសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ២១៦៥ "ព" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ ដែលត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារកំណត់រយៈពេលទាំងបីសាលក្រមចំនួន ០៨ឆ្នាំ ហើយសាលក្រមនិមួយៗត្រូវបានចូលជាស្ថាពរ រួចហើយ ។ ហេតុនេះ ស្នើសុំតុលាការសម្រេចស្រូបទោសលើទណ្ឌិតរូបនេះតាមច្បាប់កំណត់ ។

មេធាវីការពារសិទ្ធិឲ្យទណ្ឌិតឈ្មោះ ស៊ិន សុភាព បានធ្វើសេចក្តីសន្និដ្ឋាន

នៅក្នុងរឿងក្តីនេះ កូនក្តីខ្លួនពិតជាត្រូវបានតុលាការសម្រេចសេចក្តីដែលមានសាលក្រមចំនួន ០៣ និងមានទោស សរុបចំនួន ០៨ (ប្រាំបីឆ្នាំ) មែន ហើយសាលក្រមទាំងនេះ ពិតជាចូលជាស្ថាពរអស់ហើយមែន ។ ហេតុនេះ ខ្លួនសុំឱ្យ តុលាការស្រូបទោសបញ្ចូលគ្នាតាមការស្នើសុំរបស់កូនក្តីខ្លួនផង ។

Scanned with CamScanner

ឧណ្ហិតឈ្មោះ [redacted] សុភាព បានឱ្យការដ៏ចុងក្រោយ
សុំឱ្យតុលាការជួយសម្រេចស្រុបទោសបញ្ចូលដល់ខ្លួនគ្នាផង ។

ក្រោយពីបានចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ទណ្ឌិត
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១. តុលាការបានទទួលសំណុំរឿងជំនុំជម្រះលេខ ០៦ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២៣ ដែលមានទណ្ឌិតឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៨ ឆ្នាំ ប្តឹងសុំស្រុបទោសបញ្ចូលគ្នា មានលក្ខណៈ ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ តុលាការអាចលើកយកមកជំនុំជម្រះស្របតាមបញ្ញត្តិមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២. ទណ្ឌិតឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៨ ឆ្នាំ ជាសមត្ថជនមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

៣. តាមសាលក្រមព្រហ្មទណ្ឌ:

-ស្តាពរលេខ ១០៨៦ "ព"ក្រ៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បីឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ២១៣ កែងផ្លូវលេខ១៥៦ ភូមិ៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២០ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ស្តាពរលេខ ៩៥ "ព" ក្រ៧ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ (បីឆ្នាំ) ពីបទលួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចមុខហាងលក់គ្រឿងសមុទ្រម៉ាប់អយស្ទ័រ ផ្លូវលេខ២៩២ ស្ថិតនៅក្នុងភូមិ៣ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ និង

-ស្តាពរលេខ ២១៦៥ "ព" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយឆ្នាំ) ពីបទធ្វើឱ្យខូតខាតដោយចេតនា ប្រព្រឹត្តនៅចំណុចផ្លូវក្រោយរោងភាពយន្តគីរីរម្យ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៩ តាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

ឃើញថា ទណ្ឌិតឈ្មោះ [redacted] សុភាព ត្រូវបានទទួលទណ្ឌកម្មក្នុងពន្ធនាគារអតិបរមាចំនួន ០៨ឆ្នាំ (ប្រាំបីឆ្នាំ) តាមរយៈសាលក្រមស្តាពរទាំងបីខាងលើនេះ ។

៤. តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌបានចែងថា អំពើលួចមានស្ថានទម្ងន់ទោស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ០៣ ឆ្នាំ ទៅ ១០ ឆ្នាំ ក្នុងករណីដូចតទៅ៖

- អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ។
- អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ។

៥. នាពេលសវនាការទណ្ឌិតឈ្មោះ [redacted] សុភាព បានសុំឱ្យតុលាការស្រុបទោសបញ្ចូលគ្នា។ គប្បីតុលាការពិនិត្យ និងពិចារណាតាមច្បាប់ ។

៦. តាមពាក្យសុំស្រុបទោសបញ្ចូលគ្នា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ និងលិខិតបញ្ជាក់កិរិយាមារយាទលេខ ១៦១១ ម១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២៣ ចេញដោយមណ្ឌលអប់រំកែប្រែទី១ នៃក្រសួងមហាផ្ទៃ របស់ទណ្ឌិតឈ្មោះ [redacted] សុភាព បញ្ជាក់ឱ្យឃើញថា៖ ទណ្ឌិតឈ្មោះ [redacted] សុភាព បច្ចុប្បន្នកំពុងឃុំខ្លួន នៅមណ្ឌលអប់រំកែប្រែទី១ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ។ កម្រិតទោសសរុបចំនួន ០៨ (ប្រាំបីឆ្នាំ) ជាប់ពន្ធនាគារពីបទ លួចមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូតខាតដោយចេតនា ។ ថ្ងៃឃុំខ្លួនថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០២០ អនុវត្តទោសបាន ០៣ឆ្នាំ ០៣ខែ ០៨ថ្ងៃ មានដូចជា៖ ការរស់នៅមានភាពសាមញ្ញស្លូតបូតសុភាពរាបសារ ,យកចិត្តទុកដាក់រៀនសូត្រនូវមុខជំនាញដែលមណ្ឌលផ្តល់ឱ្យ ,ឧស្សាហ្យាយាមចំពោះការបំពេញការងារពលកម្មការងារពលកម្មជូនមណ្ឌល ,ចេះជួយអប់រំដល់ជនជាប់ឃុំដ៏ទៃទៀតឱ្យប្រព្រឹត្តនៅអំពើល្អ ,ខិតខំកែប្រែខ្លួនឱ្យបានល្អជាគំរូដល់ជនជាប់ឃុំដ៏ទៃ ,ចេះជួយដល់អ្នកដទៃពេលមានបញ្ហា និងគោរពបទបញ្ជាផ្ទៃក្នុងមណ្ឌលបានល្អ ។ គប្បីតុលាការពិនិត្យ និងសម្រេចស្រុបទោសបញ្ចូលគ្នា ។

<u>ហេតុដូច្នេះសម្រេច</u>

១. ទទួលពាក្យសុំស្រុបទោសបញ្ចូលគ្នា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ របស់ឈ្មោះ [redacted] សុភាព ទុកជាត្រឹមត្រូវតាមច្បាប់ ។

២. ស្រុបទោសដែលបានកំណត់ក្នុង:

ក. សាលក្រមព្រហ្មទណ្ឌស្តាពរលេខ ១០៨៦ "ព"ក្រ៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

ខ. សាលក្រមព្រហ្មទណ្ឌស្តាពរលេខ ៩៥ "ព" ក្រ៧ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

គ. សាលក្រមព្រហ្មទណ្ឌស្តាពរលេខ ២១៦៥ "ព" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ស្រុបបញ្ចូលគ្នា ។

ដោយកំណត់ឱ្យអនុវត្តទោសក្នុងពន្ធនាគារសរុបរយៈពេល ០៤ (បួនឆ្នាំ) លើទណ្ឌិតឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៨ ឆ្នាំ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២៣ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២៣

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner